Khmer Story Lovers

# បញ្ញាហែពក:

ប្រលោមលោកប្រឌិតតាមសម័យបុរាណ ចិន

ប្រលោមលោកចេញផ្សាយរៀងរាល់ថ្ងៃ ច័ន្ទ ពុធ សៅរ៍



អ្នកប្រែសម្រួល: អ.គីមសាន

តម្លៃ

ផ្សាយចេញពីក្រុមអ្នកនិពន្ធ
«មាតុភូមិ»
ភ្នំពេញ

លេខ ៥

ស៊ីយានទីអស់សំណើចនឹកថា :

–អានេះតាត់យើងជាមេចោរហើយតើ !

គាត់សួរទៀត :

– ឯងលួចលុយនេះពីណាមក ?

–យីម៉េចលោកថាខ្ញុំលួច ? ស្រីទេពអប្សរពាក់អាវសឲ្យខ្ញុំណា, លោកឃើញដែរ ?

– នរណាជាទេពអប្សរ ? អូនឹកឃើញហើយ ! គាត់នឹកឃើញអ្នកស្រីវ៉ុនយូ. នឹកទីងបន្តិច ដោយអ្នកស្រីឲ្យប្រាក់កូនស្ងួម ចាល់តែខូចការគាត់ ។ ស៊ីយានទីនាំកូនស្ងួមដើរផុតតៀមលក់និ នឹកឃើញដាវសរបស់វ៉ុនយូ ក៏សួរ :

–ដាវនេះមុតណាស់, អម្បាញ់មិញយើងកាប់ស្រាលដៃសោដាច់កូនឈើមួយដើម ។ ឯងចង់បានទេ ? បើចង់បាន សុំយើងមកយើងឲ្យភ្លាម ។

ស៊ីយានទីមិនចង់បណ្ដើរស្ងួមតួចកទុករូបនេះទេ, គាត់ចង់ឲ្យតែរកសុំអ្វីមួយទីងអាលបំបរបង់រកពេលកន្លែងណាមួយឲ្យស្រាលបន្ទុក, តែរកតួចបែរជាត្រីក្បាលស្រដីថា :

–ដាវបរិ្វងរបស់ស្រីទេពអប្សរផង់សេះពណ៌សទេតើ គាត់ចិត្តល្អណាស់ ខ្ញុំមិនត្រូវយករបស់គាត់ឡើយ ។

ស៊ិយានទឹហូតដាវខ្មៅពីក្រោមគ្រែកសត្រែកត់បង្ហាញវាម្ចាន់ ហើយសួរ :

– បើអ៊ីចឹងឯងចង់បានដាវខ្មៅនេះឬ ... ឃើញទេមុតល្អណាស់ ។

កុមារគទុកគ្រវីក្បាលដដែល :

– នេះជាដាវពូអ៊ីពាត់អាវខ្មៅដែលមកជាមួយស្រីទេពអប្សរចិត្តល្អតើ ! ខ្ញុំតែតែមិនចង់បានរបស់គាត់ទៀត ។

ស៊ិយានទឹគ្រហឹមហ៊ុះពោលបន្ត :

– កូនខ្ញុំកឯកពូជនេះមានឧត្តមគតិខ្ពង់ខ្ពស់មែន !

– ស្អីទៅដែលហៅថា ឧត្តមគតិខ្ពង់ខ្ពស់ ?

យានទឹបញ្ចេញអាកប្បកិរិយាធុញទ្រាន់ពោលសោះកក្រោះថា :

– បើមិនយល់ហើយទៅ ! ឯងគ្មានដឹងអីទេ !

កូនស្វាពោលកន្ត្រងើយ :

–អូ ! លោកមិនចូលចិត្តឧត្តមគតិខ្ពង់ខ្ពស់អីតេហ្នឹងទេឬ ? បើអ៊ីចឹង ... លោកឥតមានឧត្តមគតិខ្ពង់ខ្ពស់ដូចខ្ញុំទេ ។

ស៊ិយានទឹទឹងតូង មុខប្រែសម្បុរទៅជាខៀវយាររំងទះក្បាលកូនស្វាភ្លាម, តែលុះគ្រឡេកឃើញមុខកុកកន្លនកូនស្វា គាត់ទំនប់ដៃដកថា :

– បើកមិនយល់ន័យឧត្តមគតិបែបយើងប្រកាន់កម្មើរ ? ចាំបងនេះនិយាយបំភកទេបើលទៅ

ស៊ិយានទឹទម្លាក់ដៃចុះសួរ :

– ប៉ុនឯងហ៊ានថា យើងគ្មានឧត្តមគតិខ្ពង់ខ្ពស់ហ៎ ?

## វគ្គទី ៥

## មនុស្សល្អ និង មនុស្សអាក្រក់

កូនស្វាសួរបញ្ជាក់សិន :

–អ្នកដែលមានឧត្តមគតិ ល្អឬអាក្រក់ ?

– ល្អណាស់ ! ឧត្តមគតិតែតែខ្ពស់ តែតែល្អ ។

–អូខ្ញុំនឹកឃើញហើយអ្នកណាធ្វើល្អគេហៅជាមនុស្សល្អ, អ្នកណាធ្វើអាក្រក់គេជាមនុស្សអាក្រក់ លោកធ្វើល្អណាស់ ពិតជាមនុស្សល្អប្រពៃមានឧត្តមគតិមែនទេ ?

សំដីនេះបើចេញពីក្រអូមមាត់ជនដទៃ , សើយានទីគាត់ទុកជាសំដីជៀមដាមិគាត់ទទួលស្គាល់ភ្លាម ហើយ ព្រោះមួយជាតិនេះមិនដែលឮនរណាសរសើរថា គាត់ជាមនុស្សល្អប្រពៃសោះទេ ទោះប្រព្រឹត្តអំពើល្អខ្លះ ក៏មិនអាចទូទាត់ជាមួយអំពើអាក្រក់ទាំងអស់បានដែរ ។ គាត់ពិចារណាម្នាក់ឯងថា :

–អាតូចនេះគ្មានជំងឺអីសោះទៅឬ ? វាថាយើងគ្មានឧត្តមគតិ តែវាសរសើរយើងជាមនុស្សល្អប្រពៃ . . . បើសត្រូវយើងស្តាប់ឮច្បាស់ជាគេនិយាយដើមឆាប់ហើយ ! តោងបញ្ចប់រឿងអាតូចនេះដាច់ ១ កុំឲ្យខ្មាសគេ ។

សើនយានទី រុំដាវសេនិងដាវខ្មៅ ស្ពាយក្រោយខ្នង បន្តដំណើរជាមួយកូនស្វាមបណ្តើររិះរកមធ្យោបាយញុះញង់កុមារនេះឲ្យធ្វើសំណូមពរអ្វីម៉្យាងផង ។ មួយសន្ទុះគាត់ក្រឡេកឃើញដើមពុទ្រាខ្ពស់ ១ មានផ្លែទុំក្រហមព្រាល ក៏បន្លឺប្រាប់កូនស្វាម រួចពោលតក់ពុច :

–ផ្លែពុទ្រាទុំច្រើនណាស់រ៉ុយ !

គាត់ឃើញដើមពុទ្រាធំខ្ពស់ស្មានថាអាតូចអង្វរគាត់ឡើងបេះឲ្យវាស៊ី ស្រាប់តែស្វាមសួរវិញ :

- លោកល្អប្រពៃ ចង់ពិសាផ្លែពុទ្រាឬ ?

- ឯងហៅនរណាថាលោកល្អប្រពៃ ?

- ហៅអ៊ំឯងណា៎ ! ក្រែងអ៊ំឯងជាមនុស្សល្អឬ ?

សើយានទីប្ដូរទឹកមុខ :

- អ្នកណាថាយើងជាមនុស្សល្អ ?

- បើមិនមែនល្អមានតែអាក្រក់ , អ៊ីចឹងខ្ញុំហៅអ៊ំថាជនអាក្រក់វិញណា៎ !

- ទេយើងមិនមែនល្អ ហើយមិនមែនអាក្រក់ទៀតណា៎ !

–យីចំឡែកណាស់តើ ! ល្អក៏មិនល្អ អាក្រក់ក៏មិនអាក្រក់... អូអើនឹកឃើញហើយ ! លោកមិនមែនមនុស្សទេ ។

សើយានទីភ្ញាក់ដូចគេដាល សួរយ៉ាងរហ័ស :

– ឯងចង់ជាម៉េចចោះ ?

កូនស្ទាវសៀនគណ្ដាត ញាក់មុខដាក់គាត់ហើយស្ទុះវឹងតម្រង់ដើមពុទ្រាស្រវាចមចម្រាំងដើង រលាត់ជ្រោកទទួលស្ទាក់ទៀនដើមឈើ ។ សេយានទីមិនស្មានថាកុមារនេះរហ័សរហួនម្ល៉េះសោះពំប្រាឡេ នៃផ្លែណាទុំរលួងហើយធំៗ ញាក់ពេញហោប៉ៅទើបសម្រូតចុះមកវិញ រត់ហេបោរពុទ្រាទុំមួយដៃហុចឲ្យគាត់:

– ពិសាពុទ្រាចុះ ! អំមិនមែនមនុស្សហើយមិនមែនខ្មោចទៀត ! បែបជាទេពតាឬ ?... ខ្ញុំមើលទៅដូចជាមិនមែន ...

សេយានទីហួសហេតុគិតគំនូលពុទ្រាចំពារឃ្មុម ១ ញាប់មាត់ព្រមទាំងនឹកថា :

– អាមិនអង្វរយើងបែរជាបេះពុទ្រាឲ្យយើងហូបទៅវិញ ! អីកូនអ្នកណានេះចម្លែកដល់ហើយ !

ក្រោយនោះគាត់សួរ :

– ឯងចង់ដឹងថាយើងជានរណាដែរ ? បើចង់ដឹងអង្វរយើងក្រាបបក់ថាសុំអ៊ំជួយប្រាប់ខ្ញុំផងមើល, គេអីជាអ្វី ?

– ខ្ញុំមិនដែលអង្វរគេទេ ។

សេយានទីសួរដោយភ្ញាក់ :

– ម៉េចឯងមិនដែលអង្វរគេ ?

– អូម៉ែខ្ញុំហាមផ្ដាច់ណាស់ពាក្យនេះហ្នឹង ! គាត់ថាអាផ្ដែគតពូជកុំសុំអង្វរអ្នកណាឲ្យសោះណាមួយជីវិតឯងនេះ ។ គាត់ផ្ដាំខ្ញុំទៀតថា ស្អីក៏ដោយ, បើគេចង់ឲ្យយើងមិនបាច់សុំទេ, បើគេមិនចង់ឲ្យវិញ្ញៈយើងអង្វរទាល់អស់ទឹកមាត់ក៏គ្មានប្រយោជន៍ដែរ, មានតែធ្វើឲ្យគេតុញត្រាន់វិញ ។ តាំងពីកើតមកខ្ញុំមិនដែលសុំអីពីម៉ែខ្ញុំទេ ជួនកាលគាត់មាននំចំណីឆ្ងាញ់គាត់យកមកបង្អួតខ្ញុំ ដល់ខ្ញុំឃ្លានហាមាត់សុំ គាត់ឥតឲ្យទេ ថែមទាំងវាយតប់ខ្ញុំទៀតផងហ្នឹង !

សេយានទីឆ្ងល់ផងគល់សង្ស័យផង នឹកថា .

– ក្មេងនេះពិតជាមិនព្រមអង្វរនរណាសោះមែនឬ ? បើយ៉ាងនេះយើងសម្រេចបំណងម្ដេចបាន ? ប៉ុន្តែនេះទៀតម្ដាយវាបែបម្ដេចទេដឹង ? នរណាដែលឃើញកូនសុំនំចំណី ស៊ីបែរជាវាយធ្វើបាបកូនដូច្នេះ ?

គាត់សួរទៀត:

– ឯងធ្វើស្គមអីចឹង, បើមិនសុំទានគេបានបាយឯណាស៊ី ?

ស្គមល្អិតគ្រវីក្បាល :

– ខ្ញុំមិនដែលសុំទានគេទេ, កាលណាគេឲ្យខ្ញុំយកបើគេមិនឲ្យខ្ញុំឈរចាំមើល, ឲ្យតែគេផាកមុខឬក្រោធខ្លួនខ្ញុំយករីងរត់ត្រូយ !

សៃយានទីសើចទៀត:

– បើអីចឹងឯងមិនមែនកូនស្គមទេ , ជាកូនចោរណ៎ា !

– កូនចោរយ៉ាងម៉េចអ៊ិចេះ ?

– ឯងមិនស្គាល់កូនចោរមែនឬ ធ្វើពើហ្នឹងហ៎ះ ?

– ខ្ញុំមិនដឹងមែនបានជាសួរអ៊ីណ៎ា ! ចុះធ្វើពើគេធ្វើម៉េចដែរ ? ខ្ញុំមិនចេះទេ ។

សៃយានទីសម្លឹងមុខកូនស្គមយ៉ាងយូរ ។ ក្រោយពីដីនិងធូលីប្រឡាក់មុខស្រមក និងសក់ក្បាលកន្ទ្រើងនោះ គាត់ឃើញភ្នែកមួយគូរឡៅក្រិចក្រថ្លា ចំនងជាក្មេងឆ្លាតឆ្នុំដែរ ម៉េចក៏សួរសព្វគ្រប់ដូច្នេះ ?

គាត់ពោលមួយៗ :

– ឯងមិនមែនល្ងិតល្ងោចទេណា៎ ! អាយុជាង ១០ ឆ្នាំហើយតើ ម៉េចគ្មានដឹងខ្យល់អីសោះអ៊ីចឹង ?

– ម៉ែខ្ញុំ ឥតចូលចិត្តនិយាយជាមួយខ្ញុំដូចអ៊ំឯងទេ គាត់ថាឃើញមុខខ្ញុំគាត់ធុញណាស់ ៗ ជួនកាល ៨-១០ ថ្ងៃ គាត់មិនទាន់ហៅខ្ញុំមួយម៉ាត់ផង ខ្ញុំនិយាយតែជាមួយអាវ្លឹង ហើយអាវ្លឹងមានចេះនិយាយឯណា ? វាចេះតែស្ដាប់ ៗ អ៊ំឲ្យវាប្រាប់ខ្ញុំថា កូនចោរយ៉ាងម៉េច, ធ្វើពើយ៉ាងម៉េចកើតដែរហ៎ះ?

សៃយានទីចំពឹងមុខមាត់កូនស្គមម្ដងទៀតនឹកថា អាតូចនេះដេរម្ដាយយើងទេដឹង ?

គាត់សួរទៀត :

– បើអាវ្លឹងឯងមិនចេះនិយាយ ម៉េចឯងមិនទៅរកអ្នកជិតខាងសាកសួរគេខ្លះទៅ ?

– អ្នកជិតខាងនៅឯណា ?

– យើអើអាល្អិត ! អ្នកជិតខាង គឺមនុស្សប្រុសស្រីក្មេងចាស់ រស់នៅក្បែរផ្ទះឯងនោះណា !

– អូ . . . ឈប់ចាំនឹកមើលសិន ៗ ជិតផ្ទះខ្ញុំមានដើមស្រល់ ១០ សត្វសំពោច

ច្រើនណាស់ . . . មានមាន់ព្រៃមានទន្សាយ . . . តាហ្នឹងគេហៅអ្នកជិតខាងឬអី ? ពួកនោះឥតចេះនិយាយដូចអីទេ ចេះតែយំស្រែកចេចចាចខ្លាំងណាស់ ។

- នែ ! ក្រៅពីម៉ែឯងមានគេណាទៀតដែរ ? ឯងមិនដែលឃើញមនុស្សទេហ៎ះ ?

- បាទ ; ផ្ទះខ្ញុំនៅលើភ្នំខ្ពស់ណាស់ ឥតមានផ្លូវចុះមកទេ ហើយឥតមានគេណាក្រៅពីម៉ែទៀត ។ ថ្ងៃនោះម៉ែខ្ញុំទៅណាបាត់ បានជាខ្ញុំប្រមៀលខ្លួនចុះមកតាមរកគាត់ណា ! តាវង្វេងមកតាមខ្ញុំដែរ, ឥឡូវបាត់ទៀតហើយ ។ ខ្ញុំសួរគេថា មានឃើញម៉ែខ្ញុំនិងតាវង្វេងទេ គេឆ្លើយថាមិនដឹងទាំងអស់គ្នា . . . តាហ្នឹងអីថាខ្ញុំនិយាយរកគេឬ ?

សែរីយានទីឥតជឿត្រឹមយល់គិតថា: កូននេះរស់នៅកណ្ដាលកណ្ដាលព្រៃភ្នំជាមួយម្ដាយនិងសត្វ អ៊ីចឹងបានជាគ្មានដឹងខ្យល់អីសោះ ។

គាត់ភ្ញាក់ព្រើតនឹកឆ្ងល់ចំណុចមួយទៀតសួរភ្លាម:

-នែបើឯងល្ងង់ម្ល៉ឹងម៉េចក៏ដឹងថាគេយកលុយទិញនំស៊ី ?

-ម្សិលមិញខ្ញុំឃើញគេធ្វើអីចឹងណា ! ម្នាក់ឲ្យលុយម្នាក់ឲ្យនំ . . ឥឡូវអីចឹងបានលុយឬ ? មិនអីទេខ្ញុំឲ្យ . . .

កូនស្វាពោលផងកកាយលុយយកក្នុងថង់ទាំងអស់ហុចឲ្យសែរីយានទី ។ គាត់គ្រវីក្បាល:

-យើងមិនយកទេ ។

ព្រមទាំងលបសរសើរថា ក្មេងនេះល្ងីល្ងើតែចិត្តល្អណាស់ ។

ជជែកគ្នាយូរទៅ គាត់រឹតតែជឿថា ស្វានេះមកជួបគាត់ដោយចៃដន្យមែន គ្មានគេណាបញ្ជូនវាមកបោកប្រាស់គាត់ទេ ។ កូនស្វានៅស្ងៀមមួយស្របក់ ក៏ចាប់ផ្ដើមសួរវិញម្ដង:

- អម្បាញ់មិញអីថាខ្ញុំមិនមែនកូនស្វាទេ ជាកូនចោរទៅវិញ ។ ឥឡូវខ្ញុំជាស្អីហ្នឹង, កូនស្វាឬកូនចោរ ?

សែរីយានទីឆ្លើយទាំងញញឹម :

- បើឯងសុំលុយគេដើម្បីទិញនំ ឬ ទិញបាយស៊ី គេហៅថាកូនស្វា, តែបើសុំគេ, គេមិនឲ្យ ឯងយករបស់គេតែម្ដងគេហៅកូនចោរ , យល់ទេ ?

កូនស្វាផ្ទៀងកនឹកបន្តិច រួចឆ្លើយ :

– ខ្ញុំមិនដែលសុំស្អីគេទេ , ខ្ញុំចំណាំតែយកគ្រន់ៗ មើល , អ៊ីចឹងខ្ញុំជាកូនពៅ , អ៊ឹងឯងជាផ្ទះពោះ '

សៃយានទាំងភ្ញាក់ព្រើតគំហក :

– ថាម៉េច ? ឯងហៅយើងថាម៉េច ?

– ក្រែងអ៊ីជាផ្ទះពោះ ឬ ? ជាតិនេះមាននរណាឲ្យអ៊ីឯង ? អ៊ីឯងជណ្ដើមគេរត់ត្រុយដែរតើ ប៉ុខ្ញុំសួចធ្វើកូន, អ៊ីឯងធំត្រូវធ្វើអ៊ីចឹងហើយ ។

– ធ្វើអ៊ីចឹងគេហៅថាផ្ដេសផ្ដាស, កុំហៅយើងផ្ទះពោះទៀតឮទេ ?

– ឮហើយ ។ អ៊ឹងឯងកុំហៅខ្ញុំកូនពៅទៀតណា ! ឮទេ ?

សៃយានទាំងហួសចិត្តសើចទឹកភ្នែកថា:

– តាក្បួ« កូនពៅ » សំភប់ណែរណា ! ផ្ទះពោះក៏ផ្ដូរខ្ទះដែរ ។ ឯងមិនត្រូវដេរយើងថាផ្ទះពោះទេ ។ ឈប់ណា !

–ចុះបើអ៊ីដេរខ្ញុំដែរ...

–ចុះហើយឈប់មាត់ទៅ ! យើងឈប់ដេរឯងហើយ។ហើយឯងមិនមែនកូនស្ងួមទៀត។យើងហៅឯង «អនាថ» ហើយឯងហៅយើងថាអ៊ីចវិញ: ព្រមទេ ?

ដួចតូចត្រឹកក្បាល:

– មិនមែនអនាថទេខ្ញុំ: ឈ្មោះផ្ដុតតព្ទជ !

– យីអើ «ផ្ដុតតព្ទជ» មិនល្អស្ដាប់ទេ ។ ក្លាយឯងសាបហៅបានតែអ្នកក្រៅហៅបាន អ៊ីចឹងខុសគ្នាចុះគេដេរឯងដែរណា ក្លាយឯងចំឡែកម៉េះហៅកូនខុសគេយ៉ាងនេះមានតែកេះអី?

–ម៉េចក៏ថាមានតែកេះ ? គាត់ខ្ញុំជាផ្ដុះដេរគេលេណា បានលេងជាមួយកុំសម្បាយណាស ដូចលេងជាមួយអ៊ីដែរ ។ ប៉ុន្តែអាក្រក់ប៉េះតែត្រូវឡូវឥតដែលនិយាយតបខ្ញុំវិញទេ អ៊ីឯងបានចេះនិយាយផ្ដួចខ្ញុំ !

ពោលបណ្ដើរកូនស្ងួមលូកដៃលើក្ដៅរបស់សៃយានទឹបណ្ដើរហាក់ផ្ដួចប្រឡែងលេងជាមួយអាប៊ូ ។ សៃយានទឹបរើនគញ្ចាំងទៅខ្លួនធ្វើឲ្យកូនស្ងួមញ័រចំប្រូចផ្ដួចស្លាបម៉េះជុំដែកក្ដៅ, ពាក់លងពេញបញ្ចាំង តិងត្រូវផ្ដួលរលំក្នុង, **សៃយានខំសម៉ឺនមុខ**ពញញឹមខ្ញុំបន្ថែមថា :

– នរណាឲ្យឯងព្រះហើនដាក់យើង ? ក្មួយថ្នាំខ្លាំងម្ដងចុះ !

កូនស្ទូមតែក្រួនខ្លួនឯងពោលទាំងភ័យ :

– អ៊ំអើយ ! អ៊ំក្ដៅខ្លួនណាស់ ទៅសំពកក្រោមដើមឈើភ្លាមទៅ ខ្ញុំទៅរកទឹកឲ្យពិសា ។ អ៊ំឈឺកន្លែងណាប្រាប់ខ្ញុំផង, ក្ដៅណាស់ទាំងឈឺធ្ងន់ហើយ ។

ពោលបណ្ដើរទាញអូសដៃសៃយានទីដឹកទៅរកម្លប់ឈើ ។ កាលបើឃើញទឹកមុខស្លុតនៃស្ទូម សៃយានទី មិនដាច់ចិត្ត ចំរើនកម្លាំងកាយធ្វើបាបវាទៀតឡើយ, គាត់ឆ្លើយទាំងថា :

– អ៊ំស្រួលខ្លួនទេតើ មានឈឺអី ? ឯងស្ទាបម្ដងទៀតមើល ត្រជាក់ស្រេច ។

ពោលផងទាញដៃក្មេងតូចដាក់លើថ្ងាសគាត់ផង ។ ស្ទូមតូចស្ទាបភ្លាមស្រែកយ៉ាងប្រញាប់:

–អោយ៉ូយ ! វិវរះហើយអ៊ំ ! ត្រជាក់ណាស់ អ៊ំជិតស្លាប់ហើយ...

សៃយានទីទឹងលើសមុនតំហាក :

–ផ្ដាស ! ម៉េចថាយើងជិតស្លាប់ ?

កូនស្ទូមមុខក្រៀមផ្អេះតបថា:

–កាលមុនម៉ែខ្ញុំឈឺអីចឹងដែរអ៊ំអើយ ! ម្ដងៈក្ដៅម្ដងត្រជាក់ដូចអ៊ំដែរ ។ គាត់ស្រែកថា «អញជិតស្លាប់ហើយ ...អាប្រុសអប្រិយក្បត់ចិត្តអញ...អញស្លាប់ក៏ប្រសើរដែរ ។ កាលណោះម៉ែខ្ញុំវិះស្លាប់មែនណា ! គាត់ដេកប្រវែហលពីរខែស្រាប់តែជាឡើងវិញ ខ្ញុំភ័យណាស់ ។

សៃយានទីញញឹម :

–យើងមិនស្លាប់ទេ

កូនស្ទូមគ្រវីក្បាលព្រោះមិនជឿតាំងស្រុង, សៃយានទីនាំវាដើរទៅមុខទៀត ។ កូនស្ទូមងើយមើលព្រះអាទិត្យដែលពេលស៊ើក្ដៅស្មើរខ្លាចស្បែកក៏ដើរទៅបេះស្លឹកឈើធំៗ ញាប់ដៃ ។ សៃយានទីស្មានថាវាបេះលេងដូចក្មេងនានា ទើបមិនរវល់ឆាកមើល ។ មួយស្របក់ស្រាប់តែកូនស្ទូមហុចមួកមួយឲ្យគាត់ពាក់ :

– ក្ដៅណាស់អ៊ំ ! មានជម្ងឺត្រូវពាក់មួកណា !

សៃយានទី រំភើបចិត្តម្ដងទៀតទទួលមួកស្លឹកឈើមកពាក់ដោយរីករាយ ។ ការដើរហាលថ្ងៃក្ដៅបើមានមួកពាក់ឃើញថាស្រាន់បើដែរ ។ មិនយូរប៉ុន្មានគេទៅដល់ទីជនបទមួយតូចល្មម,

កូនសួមបន្ទឹកថា :

- អ៊ំមានដំរីនេះប្រហែលមកពីអត់លុយទិញបាយពិសារហើយ, លួចចូលគៀមស៊ីផឹកឡើងខ្លួនទៅ ។

ពោលចប់វាទាញដៃសេយានទីចូលហាងលក់បាយដែលវាឃើញមុនគេ ។ មួយជាតិនេះវាមិនដែលចូលហាងស៊ីផឹកទេ ម៉្លោះហើយវាមិនចេះហៅម្ហូបសោះ អង្គុយក្ងាមបារលុយទាំងអស់ដាក់លើតុប្រាប់អ្នកបំរើថា:

- ខ្ញុំនឹងអ៊ំខ្ញុំឃ្លានបាយឃ្លានសាច់ណាស់, ពូឯងយកលុយទាំងអស់ទៅទិញមក !

លុយវាប្រមូលមកប្រហែលជិតម៉ឺនរោះធ្វើម្ហូបចំណីពេញមួយតុក៏មិនអស់ដែរ ។ អ្នកបំរើត្រេកអរណាស់គេចូលចង្ក្រានបង្គាប់ចុងភៅធ្វើម្ហូបឆ្ងាញ់ៗលើកមកភ្លាម ។ សេយានទីហៅស្រាមួយដបមកផ្ទួម កូនសួមលើកកែវក្រេបមួយម៉ាត់ធ្វើមុខក្រញូវព្រួសស្រាពោលអស់ពោលថា :

- ហឹរណាស់ មិនឆ្ងាញ់ទេ ។

បន្ទាប់មកវាលូកសាច់ត្រីសាច់ជ្រូកស៊ីញាប់មាត់ សេយានទីមើលវាសព្វ ១ ទៅនឹកថា

- ក្មេងនេះមិនសូវដឹងគីមែន , តែមិនល្ងង់ទេ វាចិត្តល្អហើយក្លាហានណាស់ បើអប់រំព្រួលចូលប្រហែលអាចក្លាយជាមនុស្សទីងគេ ។

គាត់ឈប់មួយស្របក់ទើបគិតទៀត :

- ហ៊ឺ ! មនុស្សយើងមើលមិនឃើញទេ.. ធ្វើគុណបានទោសដូចអាសិស្សអកតញ្ញូយើងអ៊ីចឹង ? មិនត្រូវមានគំនិតរកសិស្សទៀតទេ ។

នឹកដល់សិស្សដែលធ្វើបាបគាត់,គាត់ខឹងនៅ លើកស្រាផឹកទាំងដបអស់រលីងហើយស្រែកថាទៅ !

កូនសួមសួរ:

-អ៊ំជាស្រួលបួលហើយឬ ?

-អើជាហើយកុំភ័យ ។

សេយានទីនឹកក្នុងចិត្ត:

-ឯងចាយលុយអស់ហើយអានាង ! បើចង់ស៊ីបាយទៀតត្រូវសុំយើងជាដាច់ខាត ! បើអ៊ីចឹងទៅកន្លុយលុយរាយសិន

អ្នកទាំងពីរបណ្ដើរគ្នាតម្រង់ទៅទិសខាងកើត សើយានទីសួរកូនស្ទួម :

– អានាងភ្លា ! ម្ដាយឯងត្រកូលអី ? គាត់មានប្រាប់ទេ ?

– យី ! ម៉ែនិងម្ដាយបេកមួយណាក៏បានដែរឥតមានត្រកូលទេ ។

– ពូ ! ឯងវេតទាន់ដឹងថាមនុស្សម្នាក់ ១ មានត្រកូលទេឬ ?

– អឺចឹងខ្ញុំមានត្រកូលថាម៉េចទៅ ?

– ត្រង់នេះយើងមិនដឹងដែរព្រោះឈ្មោះឯងពិបាកស្ដាប់ណាស់, ឯងចង់ឲ្យយើងដាក់ឈ្មោះឲ្យ

យានទីចង់អួតអាលឲ្យកូនស្ទួមអង្វរតែកាត្តូចមិនព្រមអង្វរសោះ, ឆ្លើយព្រងើយ :

– អ៊ីចឹងដាក់ឈ្មោះឲ្យខ្ញុំជាការប្រពៃណាស់តែខ្ញុំខាចប៉ះគេមិនឃើញណា៎ ព្រោះគាត់ធ្លាប់ហៅខ្ញុំតែអាផ្អែតពូជតាំងពីដើមមក ។ ម៉េចក៏ថាឈ្មោះខ្ញុំពិបាកស្ដាប់ !

មែន ! សើយានទីជ្រួញចិញ្ចើម ប៉ុន្តែមិនដឹងពន្យល់បែបណាឲ្យកូនស្ទួមយល់ថាឈ្មោះវាខុសគេ . ពេលកំពុងសញ្ជប់សញ្ជឹងគាត់ក្រសម្លឹងទៅរុក្ខទន្លិចគ្នាតែង ១ ដែលគុម្ពោតព្រៃខាងជ្រុងដៃស្ដាំមួយនាទី គាត់យល់ថាមានអ្នកទាំងពីរកែប្រយុទ្ធគ្នាតើព្រាប់កុមាររត់ ១ :

– យើងទៅមើលស្អីនៅខាងណោះនិ ! តែកុំមាត់ណា៎ !

ពោលហើយគាត់លូកដៃទុចចង្កេះកាត្បៀតក្បៀតសម្រាលខ្លួនតែសំដៅកន្លែងកើតហេតុ ទៅឈប់ក្រោមដើមឈើធំមួយ ។ កុមារកំសត់ទទួលអារម្មណ៍ភ្ញៀបបាមហោះហើរលើអាកាសរហាស់ពិសបាយណាស់ចង់សើចខ្លាំងតែកនិកដល់បណ្ដាំពីរ,ក៏លើកដៃខ្ទប់មាត់ស្ងាម ។

តាចាស់និងកូនកំលោសប្ដូរក្រោយគល់ឈើមើលបុរស២នាក់ប្រយុទ្ធគ្នា យ៉ាងស្វាហាប់ម្នាក់ៗលើសលប់ ។ អ្នកដែលនៅកណ្ដាលគេជាតាចាស់ដុះពុកចាត់វែងឲ្យកដល់ទ្រូងឥតកាន់អាវុធសោះទេ ។ រីឯនាក់ទៀតដែលឡោះប៉ះគ្នាគាត់សុទ្ធជាជនចំឡែក មួយមាឌស្ដមខ្ពស់មួយជាអ្នកសក់មុខរលៀង, អ្នកទីពជាបុរសមុខអាក្រក់ក្រៃលែងក្បែតមានស្លាបរបួសខ្ទេរដើងក្អែកជ្រៅត្រល់ចំកណ្ដាលថ្ពាល់ ។ -ជនស្ដមកាន់ដាវអ្នកសក់កាន់ខោង ឯជនមុខអាក្រក់កាន់កាំបិត ។

នៅពេលសើយានទី និងកុមារកំសត់ទៅដល់, តាចាស់នៅកណ្ដាលគេមានរបួសទៅហើយ តែគាត់ខំប្រឹងប្រែងទប់ទល់យ៉ាងសាហាវដោយកាន់ក្រឡឹងគល់ឈើមួយទៅមកវាយការពារខ្លួនសត្រូវ ដៃមួយចាប់

ច្បាមខ្ញាំដៃម្ខាងទះគប់ញាប់ៗ ដើរតាមស្មៀតចំខ្សែកៗ ។ សៃយានទីលបមើលមួយស្របក់ស្គាល់តាតាស់ពុកមាត់វែងក្រាមនឹកអរម្នាក់ឯង:

– យើងស្មានតែអ្នកណាមិនដឹងកញ្ចាស់តាពែម្ចាស់កោះត្រីឆ្លាមសោះ ។ ប្រសើរណាស់ថ្ងៃនេះ ខ្ញាំព្រចូលស្រុកត្រូវហ្វូងសុខទេហមកេមហើយតើ, មើលទៅគេមិនផុតពីគ្រោះកាចទេ ។

ជនបីនាក់ទៀតនោះ សៃយានទី ត់តស្គាល់ទេ តែសមជាអ្នកខ្លាំងពូកែដែរ ជាពិសេសគឺបុរសស្គមច្រើជាវហាំសរហួនស្រាលស្ទើរមើលមិនទាន់ ។ អ្នកសច្ចំត្រីមោងកញ្ញាប់ស្មកតាមស្មៀតចំខ្សែក ។ ដេញតាមតាហាស់ជុំវិញគរប់ឈើបួនដងពីមុខ ម្ដងពីចំហៀង ។ ចំណែកជនមុខកាត្រក់នោះដៃធ្ងន់ណាស់ យាវកាំបិតលើកកាប់តាហាស់ម្ដង ៗ លាន់សន្ធឹកខ្យល់វឹប ៗ ហ៊ឹងគ្រលៀក ។

សៃយានទីក្ដាក់ផ្ដើលនឹកថា :

–យើងខានចេញដើរក្នុងពិភពគុនយូរហើយ មិនដឹងមានអ្នកខ្លាំងពូកែច្រើនសោះ ។ បើជនបីនាក់នេះមិនចំណាប់តាពែនេះមិនងាយចាញ់ទេ .. ចុះបើបីនាក់នេះបែរមកវាយលុកយើងវិញយើងឈ្នះទេ ? ពិបាកវិនិច្ឆ័យដែរ...

ពេលនោះអ្នកសច្ចំបន្លឺវាចាឡើង :

–លោកម្ចាស់កោះត្រីឆ្លាមអើយ ! ក្រុមឈានល្អតគងុជាមិនមែនក្បួនជាមួយលោកទេ. ឲ្យតែលោកយល់ព្រមចុះចាញ់ ហើយចូលក្រុមបក្សយើងបកយើងធ្វើបងប្អូនគ្នាទៅ ហើយមិនបាច់ចំណាយកម្លាំងប្រយុទ្ធគ្នាទេ ។

តាពែខឹងគ្រោធតបថា:

–យើងជាកូនប្រុសដើម ១ង ៧ហត្ថ ហាស់ប៉ុណ្ណឹងហើយងាកខ្លាចស្លាប់ទេ ។ ពួកឯងយង់ឃ្នងថ្មីៗមកបបួលយើងឲ្យចូលរួមបំរើក្រុមបក្សឯងឯងឬ ? គ្មានសង្ឃឹមទេ...

ពេលដល់នេះតាពែលើកដៃច្នៃលាក្រញ៉ាប្រែងច្បាបជនមុខកាត្រក់, សៃយានទីទើបថា:

–អស្ចារ្យមែន ! នេះជាស្មៀតក្រញាំមាសដ៏ល្បីតើ !

បុរសមុខកាត្រក់ទម្លាក់ស្មាញោចបន្តិចប្រែងគេចតែតាពែហាក់ជាងច្បាប់ស្មាសត្រូវបានមុន, ជនស្គមក្រាក់ព្រើតយាវពោះបាកវឹប គម្រង់ប្រដុំចិរញ៉េបតាពែហាង៍ហើស ។ ញ្ញសូរខ្លោកគឺការជនមុខ

អាក្រក់វៃហែកមួយផ្ទាំងត្រង់ស្មាដាច់សាច់ខ្ទះផងព្រោះស្នៀតក្រញាំនាគ ក្បាច់សាហាវណាស់ មិនងាយឲ្យសត្រូវរួចខ្លួនទេ ៗ ឡើយ ។ បុរសតាំងប៉ៃឃើញគាត់ពរហ័សរហួនយកប្រៀបបានវិញ គេទាំងគ្រប់គ្នាវាយលុកកាន់តែញាប់ឡើង ។ វៃវិយានទឹងណ្ដឹងសួរ

– ក្រុមឈានល្បួមកពីណា ម្ដេចមានសមាជិកខ្លាំងពូកែច្រើនគ្នាម្ល៉េះ ? យើងមិនដែលឮឈ្មោះសោះ ។

ពេលនេះគូប្រយុទ្ធតាំងជួនវាយប្រឡូកគ្នាកាន់តែសាហាវឡើង ៗ ។ ជនមុខអាក្រក់គ្រហឹមរួចយារកាំបិតកាប់ផាំង ! គាត់គេចភ្លែតត្រៀតលូកដៃទះអ្នកសង្ឃុំ ។ ផ្លូង !.. តិប ! គាត់ទះត្រូវអ្នកសង្ឃុំ, រីឯបុរសមុខអាក្រក់កាប់ត្រូវដើមឈើកប់ផ្លែកាំបិតទំផកមកវិញ រង្គើសក់ក្បាលនៅតែមិនរបូត ។ គាត់ត្រៀតខ្លួនគាសល្អក់ញក្លួយដៃបុកចង្កេះសត្រូវពីច ។

គាត់ត្រូវគេឡោមព័ទ្ធព្រួតវាយបែបនេះឥតសង្ស័យថា រស់រានមានជីវិតទេ ។ ប្រយុទ្ធបណ្ដើរគាត់វៃពេលមើលជុំទិសបណ្ដើរ ឃើញហាក់ដូចស្រមោលមនុស្សលបមើលក្បែរៗគាត់ ក្រោយគល់ឈើដែរ ។ គាត់យល់ថាស្មុគ្គ ជាបក្សពួកឈានល្បួ ទើបគាត់មិនរវល់យកចិត្តទុកដាក់សង្កេតឲ្យដឹងច្បាស់ថានរណាឡើយ ដាងគេដឹងកាលវាយអ្នកហ្នឹងឲ្យច្រើន ម្ល៉ោះ ហើយគាត់ត្រៀតពេលជនមុខអាក្រក់ទំដកកាំបិតពីគល់ឈើវាយហើយវាយទៀត ប្រាថ្នាសម្លាប់សត្រូវមួយ ដើម្បីដោះខ្លួនរត់ ។ ពេលរុញក្លួយដៃតម្រង់ចង្កេះ ជនមុខអាក្រក់គាត់បញ្ចូនកម្លាំងជប់គាត់ប្រាថ្នាឲ្យជននេះត្រេចចង្កេះទន់ជន្ទន់ជួល ។

គាត់សម្រេចបំណង ហើយរត់ក្រឡឹងដើមឈើក្រាប ស្រាប់តែអ្នកសង្ឃុំគ្រវីមោងរត់តាមកិត, គាត់យារដៃភ្លេងទះវៃប្រវាក់ដែលចងជុំដៃក្រឹប ៗ ។ ក្នុងពេលជាមួយគ្នាពន្លឺដាវពាំងផ្លេក ៗ សព្រាតកាត់មុខគាត់,គាត់ប្រញាប់គេចទៅឆ្វេងទៅស្ដាំដែរ តែគេចមិនផុតព្រោះណាមួយគាត់អស់កម្លាំងផងណាមួយគាត់ចាស់ជរាផង លោតហក់មិនរហ័សរហួនដល់ជនពាំងប៉ៃដែលមានកម្លាំងពេញខ្លួនមាន គ្នីគ្នាជួយប្រួតដៃទេ ។

ទីបំផុតឮស្នូរឈិប ! ជនស្លុមពាក់ស្មាគាត់ពុះមុតដល់ដើមឈើចេញឈាមព្រាវ ! កុមារកំសត់ (យើងលែងហៅកូនស្ទូមហើយព្រោះវាមិនដែលសុំទាននរណាសោះ) ឃើញដូច្នេះអាណិតគាត់ណាស់គំលាន់មាត់យ៉ី ! ដោយមិនដឹងខ្លួនព្រោះវាតាមមើលធាតុប្រយុទ្ធតាំងក្ដៅក្រហាយ, វាភ្ញាប់

ដៃទាំមាត់បើកភ្នែកក្រឡោតខឹងខឹងជនបីនាក់ប្រួតគ្នាធ្វើបាបតាចាស់ណាស់ ។ ជនស្លូតសម្លក់តាពៃពោលសោះកក្រោះថា :

- ម៉េចចៅម្ចាស់កោះត្រីទ្វារ ? គេឲ្យផឹកស្រាឆ្ងាញ់មិនព្រម ចង់ភ្លក្សទឹកម្ជូរព្រៃ ? ឥឡូវសុខចិត្តចុះចាញ់ទេ ?

តាពៃបើកភ្នែកក្រឡោត ស្ដីស្រក់ឈាមតំហកដាច់ ៗ:

- ឯង... ឯងស្គាល់យើងជាម្ចាស់កោះត្រីទ្វារដែរ... ម៉េចមិនដឹងថាអ្នកកោះត្រីទ្វារ ឥតព្រមលុតជង្គង់ចុះចាញ់ជនកំសាកថោកទាបដូន...ពួកឯង ?

ចប់សំដី គាត់ខំបម្រើបម្រះរហូតដាច់ចំប៉ុកទឹង សាច់ស្លុ ហក់មកចូរជីវិតទៀត ។ អ្នកសចំគ្រីមោងហោលរុំ ! ដុំដែកប៉ះទ្រូងតាពៃព្រឺបក្អួតឈាមរកព្រាត...

កុមារទុគ៌ត ក្រាំលែងបានលែងញញើតសៃយានទីស្ទុះចេញពីគល់ឈើទាំស្រែកតំហក:

- មិនបេះខ្មាសគេទេឬ ? ប្រួតគ្នាដល់ទៅបីនាក់ធ្វើបាបតាចាស់ហ្នឹង ? មិនត្រឹមត្រូវទេ... មិនល្អទេ !

សៃយានទឹងចង់ចិញ្ចើមខឹងថា គាល្អិតនេះចង្រៃណាស់តើ ករចេញទៅបន្តរៀនវគ្គថ្មី ! អើ ! ម៉្យាងដែរ. .បើបណ្ដោយឲ្យជនអស់នេះសម្លាប់វាទៅ យើងមិនខុសអីទេ... ចាំមើលមើលក្នុងពេលភាសន្ននេះតើវាសំពះអង្វរឲ្យយើងជួយជីវិតឬទេ ? ឥឡូវជនម្នាក់របួសធ្ងន់ហើយនៅសល់តែពីរប្រៀបបាលយើងមានផ្លូវឈ្នះ ។

ពេលនោះកុមារកក្ខក់តែទៅឈរពាំងមុខតាពៃស្រែកខ្លាំងៗ :

-ពួកឯងឈប់ធ្វើបាបតាចាស់នេះទៅ !

ជនស្លូតសម្លក់សម្លឹងក្រមប់គល់ឈើកេមនុស្ស ស្រាប់តែលេចក្មេងតូចក្លាហានមកវិញគេមិនអស់ចិត្តឡើយខឹងថាច្បាស់ជាមាននរណាបង្គាប់វាឲ្យចេញមកហើយ, ដូច្នេះត្រូវចំកីយាគាតូចនេះទៅច្បាស់ជាមនុស្សធំចេញមកធ្វើអន្តរាគមន៍មិនខាន ។

គិតឃើញដូច្នេះគេដកដាវចេញពីដើមឈើស្រែកគំរាម:

-អាខ្មោចល្អិត អ្នកណាប្រើឯងមករវីររវាមត្រង់ណេះ ? យើងសម្លាប់កញ្ចាស់នេះហើយ ចៀសចេញភ្លាមឡើង !

ពោលចប់គេលើកដាវផ្ទួ ដូចចង់កាប់ទទឹងខ្នងវាតែកុមារចំឡែកពោលតាមជម្នាក :

– តានេះជាមនុស្សល្អ, ឯងជាមនុស្សអាក្រក់...ខ្ញុំត្រូវជួយមនុស្សល្អ, បើឯងចង់កាប់ខ្ញុំកាប់មកចុះខ្ញុំមិនចៀសទេ ។

ត្បិតកុមារនេះនៅជាមួយម្ដាយធ្លាប់ ឮម្ដាយពន្យល់ពីមនុស្សល្អមនុស្សអាក្រក់ហើយខ្លួនបានឲ្យជួយយកអាសាមនុស្សល្អខ្លះដែរ ទើបវាហ៊ានពោលបែបនេះ ។

ផនស្គមនៅតែគំហក :

– ឯងស្គាល់កញ្ចាស់នេះដែរ, ម៉េចហ៊ានថាវាជាមនុស្សល្អ ?

– អម្បាញ់មិញលោកតាថាឯងជាមនុស្សមិនត្រឹមត្រូវគាត់សុខចិត្តស្លាប់មិនព្រមចុះចូលនោះអី ? អាហ្នឹងហើយគេថាគាត់ល្អណា៎ !

វាពោលផងងាកក្រោយផងលូកដៃប្រួងស្រាយច្រវាក់ដែលរុំព័ទ្ធតាតៃ តែអ្នកសច្ចំទះតន្ត្រៀងវាដាំងងឹតមុខហើមថ្ពាល់ក្រហមលេណដំលេចស្នាមម្រាមដៃប្រាំច្បាស់ទេង ។ កុមារនេះមិនញញើតអ្វីសោះទេ ឃើញរឿងហេតុថ្ពាល់ក្ដៅយ៉ាងណា វាពិចារណាតាមនោះដោយឥតឪកនាថាមនុស្សធំគាចមានគំនុំគុំគួនតាំងពីដើមឡើយ ។

កាលនៅភូមិហ្វូវជានវាចង់ជួយព្រោះអ៊ីជូរច្ចេះដែរ តែជួយមិនទាន់ព្រោះលីតាយានចាក់ស្លាប់ភ្លាម ។ ពេលនេះទៀតផនស្គមសង្ស័យណាស់ មិនដឹងក្មេងក្រោកសំអាងអ្វីបានជាមិនខ្លាចស្លាប់ ? គេទោលភ្នែកវាតែមើលក្រោយគល់ឈើស្រពិចស្រពិលដូចសិយានទីម្ចាស់បញ្ជាដែកសំរិទ្ធ ម្ល៉ោះហើយគេលើកដាវស្រែកគំហក :

–យើងមិនដឹងឯងមកពីណាបក្សពួកនរណាទេ, យើងដឹងតែម្យ៉ាងថាឯងសោគអ. ភ្ជាគមកពីណានៅយើងគ្មានខ្លាចអីសោះគឺឯងជាកូនកំពូលក្នុងប៉េនីប្រុះហេ យើងត្រូវសម្លាប់ឯងចោល ។

ពេលចប់គេលើកដាវកាប់សំដៅតញ្ញកុមារកំសត់ តែក្មេងនេះក្លាហានណាស់ឥតខ្វល់រើកបន្តិចណាសោះ បណ្ដាលឲ្យផននោះកោតស្ញប់ស្ញែងពោល :

– អាល្អិតនេះក្លាហានគ្រាន់បើ !

អ្នកសច្ចំចិត្តក្ដៅជាងគេយារដៃទះកំផ្លៀងកុមារម្ដងទៀតខ្លាំងជាងមុន, ក្មេងតូចឈឺចាប់ក្រៃលែងស្រែកយំហ៊ូ ; ផនសំគមក៏ញញឹម

– បើឯងចេះឈឺម៉េចមិនតែពេញ !

កុមារកំសត់តបទាំងអណ្តឺតអណ្តក:

–ឯងដើរចេញសិនទៅ កុំធ្វើបាបតាចាស់នេះទៀតបានខ្ញុំទៅកើត ។

ជនសំគមញួសចិត្ត ឆ្កួតសម្ដីរកនៃទឹងលើកដំបងវាត់វាមួយចុងជួលទេក្នុងហើយបុះហើយហាត់ តែក ទំប្រវេប្រវាក្រោកទៅឈរគោរពារតាពៃដដែល –។ តាពៃចំឡែកណាស់, មួយជាតិនេះគ្មានមិត្តភក្ដិស្មោះស្មាលមួយគ្រាប់សោះ ។ កាលះឃើញក្មេងកំព្រាស្ទៀកពាក់យ៉ើរយ៉ើមកជួយគាត់ទទេ ដូច្នេះគាត់ត្រេកអរណាស់ ពោលល្អន់លាម :

– តាទៅហើយ កុំប្រឆាំងតទល់នឹងពួកពាលៃស្លាប់ឥតអាណាពេ, តាបានសំណាង គ្រាន់បើ ទើបជិតស្លាប់បានជួបក្មេងចិត្តល្អក្លាហានដូចឯង.... ខ្សូរឆាប់ទៅ ។

កុមារមិនយល់សំដីតាចាស់ទាំងអស់ទេ គ្រាន់តែដឹងថាគាត់បន្ទំពាក្យចាកចេញពីទីនេះ តែក៏ស្រែក ថា:

– លោកតាជាមនុស្សល្អមិនត្រូវនៅឲ្យមនុស្សអាក្រក់ធ្វើបាបទេ ។

ជនសំគមមិនទាន់ដាច់ចិត្តធ្វើបាបក្មេងតូច ព្រោះគេខ្វល់បំពងទាត់បាត់ ដោយហេតុក្រលេចមកដោយ វៃឥឡូវពេក ហើយមិនដឹងថាជនពួនលបមើលក្រោយគល់ឈើជាសៃយានទិព្វប៉ុន្មាន ? បើងមិន ចង់ជួបសត្រូវទេ , តែបើឲ្យតាតូចនេះងាយពាក្យពេក យើងនាំគ្នាដើរចេញដូចជាក្រុមឈានល្ង កំសាកពេក ។

ដោយនឹកឃើញបែបនេះ ទើបគេលើកដាវជន្ទ្រប់ហើយបង្អើកថា :

– មិនអីទេតាតូច ! តាមានចាំយើងសាកក្បាលឯងមើលសិន កាប់សាយសិបប៉ុណ្ណឹងយ៉ាងណា ! បើឯងមិនកម្រើកយើងសុខចិត្តចុះចាញ់ ។ ហ៊ានខ្លាចទេ ?

– បើកាប់ខ្ញុំញាប់ដាវខ្ញុំខ្លាចណាស់ ។

– តើ ! បើខ្លាចតែចេញពីនេះឲ្យឆាប់ទៅ ។

– ខ្ញុំគ្រាន់តែខ្លាចមើលឲ្យខ្ញុំចៀសចេញ ? ខ្ញុំមិនទៅណាទេ ។

ជនសំគមលើកព្រហាមដៃពោលសរសើរ :

– ឯងពិតជាក្មេងក្លាហានមែន, ប្រយ័ត្នណា !

គេពោលហើយយាត្រដាវពាត់វែច ៗ តែស្រូវខ្លួនក្មេងតូច ។ សៃយានទិព្វលបមើលឃើញគេបញ្ចេញ

ស្ទៀតដាវយ៉ាងប្រណីតញាប់ក្រៃលែងៈឃើញតែពន្លឺដាវភ្លូត ៗ គួរឲ្យស្ញើប ៗ មួយដាវដំបូងគេ កាត់ទទឹងក្បាលក្មេងដាច់សក់រជ្រុះរពុយ ក្មេងតូចមានៈមែនរ៉ាឈរត្រង់ខ្លួនបើកភ្នែកក្រឡេតឥតខ្ចីព្រិច ៗ ដាវដនសំគមដេញស្ទើរព្រាត ៗ ដូចសត្វពស់ល្មូនលើផ្ទៃទឹក ៗ

ដនសំគមកាប់ក្មេងកាប់ស្តាំ បញ្ឆិតក្បាលកុមារក្លាហានជ្រុះសក់រពុយរោយរោះព្រាងព្រាត ៗ ដល់យារដាវតែរប់ ៣២ ដននោះស្រែកព័សលើកដាវសំពងពីលើចុះក្រោមពុះរិប គួរព្រឺក្បាលដាច់ជាពីរស្តាំ កុមារកំសត់មួយបន្ទះធំ ៗ ដាវទី ៣៤ ត្រូវកាប់ពុះរិបម្តងទៀត ដាច់ជាពីរស្តាំជ្រុះដី ៗ ស្ទៀតដាវទី ៣៥ និង ៣៦ ត្រូវដើរខាងទាំងសងខាងដាច់មួយដុំ ៗ ជាកិច្ចបង្ហើយ ៗ ដនសំគបដកដាវមកវិញ បង្វិលដងចុចដីពចរតាំតែយ៉ាងដំណំ រួចទើបស្រែចហាសៗ :

– តាងនេះ ក្លាហានណាស់ហ៊ុយ !

តែបើហានទីលបស្រសើរដនសំគមក្នុងពោះរហូតដល់ឃើញចុចដីពចរតាំតែ ថែមយ៉ាងសាហាវគំព្រីគ្គីងខ្លួនត្រឹក្បាលរលៀនអណ្តាត ៗ ដល់ងាកមើលក្មេងតូចមិនៈឃើញសក់ក្បាលគន្រ្ទីងដូចមុន បែរជាឃើញក្មេងត្រដោលដំចំឡែកទៅវិញ ៗ ចំណែកក្មេងតូចដែលនៅស្ងៀមមិនកំរើក បណ្តោយឲ្យគេកាប់លាវដាវម៉ែនមែនបានន័យថាក្លាហាននោះទេ តាំងពីក្បាលជ្រុលសូន់ដើងដៃឈរថ្មីងដូចរូបសំណាកទេតើ ?

ដល់ពេលដនសំគមស្រែកព័សហើយស្រែចហាស ៗ ទើបវាហ៊ានលើកដៃស្ទាបក្បាល ៗ លុះឃើញក្បាលនៅជាប់នឹងស្មាដដែលវាដកដង្ហើមយូរបន្តិច...

អ្នកសប្តំនិងជនមុខតាក្រក់ស្រែកហៅព្រមគ្នា :

– ណោកទី ! គុនដាវណោកពូកែអស្ចារ្យមែន !

ដនសំគមតប :

– ក្មេងនេះក្លាហានមែន ! ណ្ហើយយើងបើកផ្លូវឲ្យវាដើរផង ៗ មកជូនទាំងពីរត្រឡប់ទៅវិញ ៗ

(នៅមានត)

Khmer Story Lovers

ដីកាល់ទុកតាមលេខ ២៩១ ចុះថ្ងៃទី ១៨ ៥-៧០ បោះពុម្ពលើកទី ១ ចំនួន ២០០០ ច្បាប់